**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៦៣ ❖ ៤៧

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៦១១ អយក.ប្រក

## ប្រកាស

**ស្ដីពី ការបើកសាលាបឋមសិក្សា ឈើនាលត្លោះ**
**ជាសាលាបឋមសិក្សា ពេញលក្ខណៈ**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ស្ដីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ របស់គណៈកម្មការសាងសង់សាលាបឋមសិក្សា **ឈើនាលត្លោះ** ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២ ដោយមានចំណារឯកភាពរបស់មន្ទីរ អប់រំយុវជន និង កីឡាខេត្ត **កណ្ដាល** ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

**ស ំ រេ ច**

**ប្រការ១** : បើកសាលាបឋមសិក្សា **ឈើនាលត្លោះ** ដែលមានទីតាំងស្ថិតនៅភូមិ **ឈើនាលត្លោះ** ឃុំ **ស្វាយអំពារ** ស្រុក **មុខកំពូល** ខេត្ត **កណ្ដាល** ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ឈើនាលត្លោះ** ត្រូវដឹកនាំដោយ នាយក១រូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត **កណ្ដាល** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **មុខកំពូល** នាយកសាលាបឋមសិក្សា **ឈើនាលត្លោះ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលាខេត្ត **កណ្ដាល**

**"ដើម្បីជូនជ្រាបជាព័ត៌មាន"**

-ដូចប្រការ ៤
-កាលប្បវត្តិ-ឯកសារ-នា-បស

ភ្នំពេញ, ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០០៣
**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**
**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**